ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អត្ថបទស្រាវជ្រាវ

# តួនាទីអាជ្ញាសាលាក្នុងការអនុវត្តដោយបង្ខំ


បង្រៀនដោយ៖ សាស្ត្រាចារ្យ ខាំ សុមករា
រៀបរៀងដោយ៖ និស្សិតក្រុមជី៩ *(BBU)*



Shared by page: Mr. That Chantha
https:///www.facebook.com/thatchantha

# មាតិកា

**សេចក្តីផ្តើម**

**មាតិកា**

**I. តួនាទីសំខាន់ៗរបស់អាជ្ញាសាលា**

១. ការអនុវត្តចំពោះចលនវត្ថុ....................................................................................១

២. ការអនុវត្តសិទ្ធិប្រាតិភោគចំពោះចលនវត្ថុ.....................................................................៧

៣. ការអនុវត្តឲ្យប្រគល់ចលនវត្ថុ និងអចលនវត្ថុ...............................................................១០

**II. តួនាទីបន្ទាប់បន្សំរបស់អាជ្ញាសាលា**

១. ការថែរក្សាគ្រប់គ្រងអចលនវត្ថុ...............................................................................១១

២. ការអនុវត្តការលក់អចលនវត្ថុ..................................................................................១២

៣. ការដកសញ្ញាតិនាវា...........................................................................................១៣

**សេចក្តីសន្និដ្ឋាន**

**ឯកសារយោង**

Shared by page: Mr. That Chantha
https:///www.facebook.com/thatchantha

## សេចក្ដីផ្ដើម

***តើអាជ្ញាសាលាជានរណា?*** អាជ្ញាសាលា ជាស្ថាប័នយុត្តាធិការឯករាជ្យមួយ ដែលទទួលបន្ទុកធ្វើការបញ្ជូនឯកសារនានា ដែលចេញដោយតុលាការ និងធ្វើការអនុវត្តដោយបង្ខំមួយចំនួនដែលច្បាប់កំណត់។ បច្ចុប្បន្ននេះគ្មានអាជ្ញាសាលាទេ គឺមានតែមន្ត្រីទទួលបន្ទុកកិច្ចការសាលាអាជ្ញាសាលាប៉ុណ្ណោះ។ ព្រះរាជអាជ្ញា គឺជាមន្ត្រីទទួលបន្ទុកកិច្ចការសាលា តាមប្រកាសលេខ៣០ ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០៧ របស់ក្រសួងយុត្តិធម៌។ អាជ្ញាសាលា គឺជាមន្ត្រីរាជការដែលមានឋានន្តរសក្តិ ក៣-១៤ ក្នុងក្រមខណ្ឌក្រសួងយុត្តិធម៌ ដែលត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យ តាមសំណើររបស់ក្រសួងយុត្តិធម៌[1] ។ អាជ្ញាសាលា ត្រូវអនុវត្តកិច្ចការដែលក្រមនីតិវិធីរដ្ឋប្បវេណី ក្រមនីតិព្រហ្មទណ្ឌ ឬបទដ្ឋានគតិយុត្តិផ្សេងៗទៀត កំណត់ថាត្រូវអនុវត្តដោយអាជ្ញាសាលា និងកិច្ចការពាក់ព័ន្ធនឹងការរក្សាការគ្រប់គ្រងវត្ថុ ឬសកម្មភាពផ្សេងៗទៀត ដែលសេចក្តីសម្រេចរបស់តុលាការកំណត់ថាត្រូវចាត់ចែងដោយអាជ្ញាសាលា[2] ។

***ដូចម្តេចដែលហៅថា អនុវត្តដោយបង្ខំ?*** ការអនុវត្តដោយបង្ខំ គឺជាប្រព័ន្ធមួយដែលមានលក្ខណៈបង្ខំពីសំណាក់រដ្ឋ ដើម្បីជួយសម្រេចសិទ្ធិរបស់ បុគ្គលណាដែលមានសិទ្ធិទាមទារ ឬសិទ្ធិប្រាតិភោគ ដែលមានកំណត់ក្នុងលិខិតអនុវត្ត។ ការអនុវត្តដោយបង្ខំ គឺផ្អែកលើក្រមនីតិវិធីរដ្ឋប្បវេណី ដែលមានចែងក្នុងគន្ថីទី៦ ចាប់ពីមាត្រា ៣៣៤ ដល់មាត្រា៥២៩ ដែលស្មើនឹង ១៩៥មាត្រា ហើយការអនុវត្តដោយបង្ខំនេះ ត្រូវអនុវត្តផងដែរចំពោះដីកាសម្រេចរក្សាការពារ។

## I. តួនាទីសំខាន់ៗរបស់អាជ្ញាសាលា

### ១. ការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ

#### ១.១. ការដាក់ពាក្យសុំអនុវត្ត

ពាក្យសុំអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ដោយប្រាប់ពីទីកន្លែងដែលចលនវត្ថុស្ថិតនៅ ហើយយកទៅជូនអាជ្ញាសាលានៃសាលាដំបូងដែលចលនវត្ថុនោះស្ថិតនៅ។ ពាក្យសុំនោះពុំចាំបាច់ ចង្អុលប្រាប់នូវចលនវត្ថុណាមួយដែលត្រូវរឹបអូសនោះទេ ពោលគឺគ្រាន់តែប្រាប់នូវទីកន្លែងឲ្យបាន

---

[1] មាត្រា៨ កថា.១ និងមាត្រា៩.កថា.១ នៃសេចក្តីព្រាងច្បាប់ស្តីពីអាជ្ញាសាលា។

[2] មាត្រា៨ កថា.៤ នៃសេចក្តីព្រាងច្បាប់ស្តីពីអាជ្ញាសាលា។

ច្បាស់លាស់តែប៉ុណ្ណោះ ព្រោះការកំណត់នូវចលនវត្ថុដែលត្រូវរឹបអូសជាភារកិច្ចរបស់អាជ្ញាសាលា។ ចលនវត្ថុនៅទីនេះរាប់បញ្ចូលទាំងផល ធម្មជាតិដែលមិនទាន់បំបែកចេញពីដីនៅឡើយ ហើយដែលអាចនឹងទទួលផលបានយ៉ាងច្បាស់លាស់នៅក្នុងកំឡុងពេល ១ខែ។ មុននឹងចាប់ផ្តើមរឹបអូស ប្រសិនបើបានជួបកូនបំណុលនៅកន្លែងដែលត្រូវរឹបអូស អាជ្ញាសាលាត្រូវដាស់តឿន ឲ្យកូនបំណុលនោះសងបំណុលនោះដោយស្ម័គ្រចិត្តជាមុនសិន។ ការអនុវត្តដោយបង្ខំ នឹងត្រូវចាប់ផ្តើមដោយការរឹបអូសចលនវត្ថុដែលជាកម្មវត្ថុដោយអាជ្ញាសាលា ផ្អែកលើលិខិតអនុវត្ត និងពាក្យសុំឲ្យអនុវត្ត[3] ។

## ១.២. របៀបនៃការរឹបអូស

### ក. ចលនវត្ថុកាន់កាប់ដោយកូនបំណុល

ក្នុងករណីធ្វើការរឹបអូសចលនវត្ថុដែលកាន់កាប់ដោយកូនបំណុល អាជ្ញាសាលាត្រូវធ្វើដោយកាន់កាប់ចលនវត្ថុនោះហើយពុំចាំបាច់ស្រាវជ្រាវអំពីកម្មសិទ្ធិទេ ពោលគឺផ្អែកតែទៅលើរូបភាពខាងក្រៅនៃការកាន់កាប់របស់ កូនបំណុលប៉ុណ្ណោះ។ ដោយហេតុថា ចលនវត្ថុដែលកូនបំណុលកាន់កាប់ដោយផ្ទាល់ ភាគច្រើនជាកម្មសិទ្ធិរបស់កូនបំណុលនោះ ហេតុនេះហើយ រាល់ចលនវត្ថុដែលកាន់កាប់ដោយកូនបំណុល អាចត្រូវរឹបអូសបានទាំងអស់។ ប៉ុន្តែបើចលនវត្ថុដែលបានរឹបអូសនោះ ជាកម្មសិទ្ធិរបស់បុគ្គលដទៃ ម្ចាស់កម្មសិទ្ធិអាចប្តឹងតវ៉ាដើម្បីការពារផលប្រយោជន៍របស់ខ្លួនបាន។ ប្រសិនបើមានការរារាំងនៅពេលធ្វើការរឹបអូស អាជ្ញាសាលាអាចប្រើកម្លាំងបង្ខំបាន និងអាចចូលទៅទីកន្លែង រស់នៅ ឬកន្លែងផ្សេងទៀតដែលកាន់កាប់ដោយកូនបំណុល ព្រមទាំងអាចធ្វើការឆែកឆេរ ដើម្បីស្វែងរកចលនវត្ថុ ដែលអាចរឹបអូសបាន ហើយថែមទាំងអាចធ្វើការចាត់ចែង ដើម្បីបើកទ្វារដែលបិទ ទូដែក ឬប្រអប់ផ្សេងទៀតបាន[4] ។

### ខ. ចលនវត្ថុកាន់កាប់ដោយម្ចាស់បំណុល ឬតតិយជន

ក្នុងករណីដែលចលនវត្ថុដែលជាកម្មវត្ថុនៃការអនុវត្ត ត្រូវបានកាន់កាប់ដោយម្ចាស់បំណុល នោះការអនុវត្តដោយបង្ខំនឹងមានភាពងាយស្រួល និងឆាប់រហ័ស ព្រោះម្ចាស់បំណុលប្រាកដជាប្រគល់ចលនវត្ថុដោយស្ម័គ្រចិត្ត ទៅឲ្យអាជ្ញាសាលាធ្វើការរឹបអូសដើម្បីសម្រេចបាននូវការទាមទារបំណុលរបស់ខ្លួន។

---

[3] មាត្រា ៣៨៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

[4] មាត្រា ៣៨៥/១-២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

ក្នុងករណីដែលចលនវត្ថុរបស់កូនបំណុលដែលជាកម្មវត្ថុនៃការអនុវត្ត ត្រូវបានកាន់កាប់ដោយតតិយជនវិញ អាជ្ញាសាលាអាចធ្វើការរឹបអូសបាន លុះត្រាតែតតិយជនយល់ព្រមអំពីការប្រគល់។ ប្រសិនបើតតិយជនមិនព្រម ប្រគល់នូវចលនវត្ថុទេនោះ អាជ្ញាសាលាពុំអាចប្រើកម្លាំងបង្ខំ ឬចូលទៅក្នុងកន្លែងរស់នៅរបស់តតិយជនដើម្បីឆែកឆេរបានឡើយ។ ក៏ប៉ុន្តែក្នុងករណីនេះ ម្ចាស់បំណុលអាចដាក់ពាក្យសុំទៅតុលាការឲ្យធ្វើការអនុវត្តដោយបង្ខំចំពោះ សិទ្ធិលើបំណុល ដែលកូនបំណុលនោះមានចំពោះតតិយជន ដើម្បីធ្វើការរឹបអូស ឬទាមទារឲ្យប្រគល់ចលនវត្ថុនោះបាន[5] ។

### ១.៣. ការដាក់កម្រិតទៅលើការរឹបអូស

#### ក.ការមិនអនុញ្ញាតឲ្យរឹបអូសហួសប្រមាណ

ការរឹបអូសចលនវត្ថុ គឺត្រូវធ្វើឡើងត្រឹមកម្រិតដែលចាំបាច់សម្រាប់ សងបំណុលសិទ្ធិលើបំណុលរបស់ម្ចាស់បំណុល និងសោហ៊ុយសម្រាប់ការអនុវត្តតែប៉ុណ្ណោះ។ ដោយសារតែ ការអនុវត្តដោយបង្ខំមានគោលបំណងត្រឹមតែ ដើម្បីសម្រេចនូវសិទ្ធិទាមទារដែលបានកំណត់ក្នុងលិខិតអនុវត្ត ដូច្នេះការរឹបអូសហួសពីទំហំចាំបាច់ដែលបាន កំណត់នោះ គឺជាការគាបសង្កត់ទៅលើកូនបំណុលយ៉ាងធ្ងន់ធ្ងរ។

ម៉្យាងទៀត ក្រោយពេលបានរឹបអូសរួចហើយ បើបានដឹងយ៉ាងច្បាស់ថា ការរឹបអូសនោះហួសពីកម្រិត ចាំបាច់ដែលបានកំណត់ អាជ្ញាសាលាត្រូវលុបចោលនូវកម្រិតដែលលើសនោះ។ ដោយហេតុថា ការអនុវត្ត ដោយបង្ខំចំពោះចលនវត្ថុ លទ្ធភាពនៃការរឹបអូសហួសប្រមាណមានកម្រិតខ្ពស់ ពីព្រោះ ចលនវត្ថុដែលត្រូវ រឹបអូសពុំត្រូវបានកំណត់ជាក់លាក់នៅក្នុងពាក្យសុំអនុវត្តទេ។ ដូច្នេះទើបច្បាប់តម្រូវឲ្យអាជ្ញាសាលាលុបចេញនូវកម្រិតដែលលើសនោះ[6] ។

#### ខ. ការមិនអនុញ្ញាតឲ្យរឹបអូស បើគ្មានចំនួនសេសសល់

បើប៉ាន់ប្រមាណឃើញថា ទឹកប្រាក់ដែលបានមកពីការលក់ចលនវត្ថុនោះពុំមានចំនួនសេសសល់ទេ ក្រោយពីបានសងសោហ៊ុយសម្រាប់នីតិវិធីរួចហើយ ឬក្រោយពីបានសងសិទ្ធិលើបំណុលដែលមានអាទិភាព ជាងសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនៃការអនុវត្ត និងសោហ៊ុយសម្រាប់នីតិវិធី អាជ្ញាសាលាមិនត្រូវធ្វើការ រឹបអូស

---

[5] មាត្រា ៣៨៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

[6] មាត្រា ៣៩១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

ឡើយ ឬត្រូវតែលុបចោលការរឹបអូសនោះ។ ដោយសារតែ ការអនុវត្តដោយបង្ខំធ្វើឡើងដើម្បីយកប្រាក់ ទៅសងឲ្យម្ចាស់បំណុល។ ដូច្នេះ នៅពេលរឹបអូសបើប៉ាន់ប្រមាណឃើញថានៅតែគ្មានប្រាក់សងដដែល នោះការរឹបអូសពុំមានផលប្រយោជន៍អ្វីទេ ហើយថែមទាំងជាការធ្វើបាបកូនបំណុលដោយគ្មានន័យទៀតផង[7] ។

### ១.៤. ការគ្រប់គ្រងចលនវត្ថុដែលបានរឹបអូស

ជាគោលការណ៍ បើចលនវត្ថុដែលត្រូវបានរឹបអូសរួចហើយនោះ ងាយស្រួលក្នុងការដឹកជញ្ជូន និងទុកដាក់ផងនោះ គឺត្រូវស្ថិតនៅក្រោមការគ្រប់គ្រងថែរក្សារបស់អាជ្ញាសាលា។ ក៏ប៉ុន្តែ ចំពោះចលនវត្ថុដែលពិបាក និងអស់សោហ៊ុយច្រើនក្នុងការដឹកជញ្ជូន ឬក៏ពិបាកក្នុងការថែរក្សាទុកនោះ បើយល់ឃើញថាសមរម្យ អាជ្ញាសាលាអាចឲ្យកូនបំណុលនៃការអនុវត្ត គ្រប់គ្រងថែរក្សាបន្តទៀតបាន ដោយអនុញ្ញាត ឬមិនអនុញ្ញាតឲ្យប្រើប្រាស់។ ក្នុងករណីនេះ ត្រូវមានស្លាកបញ្ជាក់ឲ្យដឹងថា ជាចលនវត្ថុត្រូវបានរឹបអូស ឬដោយវិធី ដាក់សញ្ញារឹបអូសផ្សេងទៀត[8] ។

ម្យ៉ាងទៀត បើចលនវត្ថុដែលត្រូវបានរឹបអូសរួចហើយ បែរជាធ្លាក់ទៅនៅក្រោមការកាន់កាប់របស់ តតិយជនដោយការចាត់ចែងរបស់កូនបំណុលនៃការអនុវត្តនោះ សាលាដំបូងដែលអាជ្ញាសាលាស្ថិតនៅ អាចបង្គាប់ឲ្យតតិយជន ប្រគល់ចលនវត្ថុនោះទៅអាជ្ញាសាលាវិញ តាមពាក្យសុំរបស់ម្ចាស់បំណុលដោយដីកាសម្រេច។ ពាក្យសុំត្រូវធ្វើក្នុងរយៈពេល ១សប្តាហ៍ គិតពីថ្ងៃដែលបានដឹងអំពីការកាន់កាប់ ហើយដីកាសម្រេចនេះ អាចប្តឹងជំទាស់បាន។ ប៉ុន្តែដីកាសម្រេចបង្គាប់ឲ្យប្រគល់ចលនវត្ថុដែលបានត្រូវរឹបអូសនេះ ពុំអាចយកទៅអនុវត្តបានឡើយ បើអំឡុងពេល ២សប្តាហ៍ បានកន្លងហួស គិតពីថ្ងៃបានផ្តល់ដំណឹងដល់អ្នកស្នើសុំ[9] ។

### ១.៥. អានុភាពនៃការរឹបអូស

អានុភាពនៃការរឹបអូស មានវិសាលភាពទៅលើផលធម្មជាតិដែលកើតចេញពីចលនវត្ថុដែលបានរឹបអូស ហើយចលនវត្ថុនៅទីនេះ រាប់បញ្ចូលទាំងសត្វពាហនៈ ឬសត្វចិញ្ចឹមផងដែរ។ ក្នុងករណីនេះ ទោះបីជាចលនវត្ថុ នោះទុកឲ្យកូនបំណុលគ្រប់គ្រងថែក្សា និងអាចប្រើប្រាស់ដោយមានការអនុញ្ញាតពីអាជ្ញាសាលាក៏ដោយ ក៏កូនបំណុលនោះពុំមានសិទ្ធិទទួលផលដែលកើតចេញពីចលនវត្ថុនោះដែរ មានដូចជា ផ្លែឈើ កូនសត្វចិញ្ចឹម ឬ

---

[7] មាត្រា ៣៩២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

[8] មាត្រា ៣៨៥/៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

[9] មាត្រា ៣៩០ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

ស៊ុតជាដើម[10] ។ ក្នុងករណីដែលរថយន្ត ឬទោចក្រយានយន្តដែលត្រូវបានរឹបអូសមានចុះបញ្ជីនៅក្នុងសៀវភៅចុះបញ្ជីអានុភាពនៃការរឹបអូសនឹងត្រូវកើតឡើងនៅពេលដែលអាជ្ញាសាលាផ្ទុកផ្ដាក់ឲ្យស្ថាប័នមានសមត្ថកិច្ច សរសេរនូវហេតុការណ៍នៃការរឹបអូសចូលទៅក្នុងសៀវភៅចុះបញ្ជីនោះ[11] ។

## ១.៦. ការលក់ចលនវត្ថុដែលបានរឹបអូស

មុននឹងធ្វើការលក់នូវចលនវត្ថុដែលត្រូវបានរឹបអូស អាជ្ញាសាលាត្រូវជូនដំណឹងជាសាធារណៈអំពីចលនវត្ថុដែលត្រូវដាក់លក់ និងវិធីលក់ ដោយការបិទប្រកាសនៅតុលាការ។ របៀបលក់ចលនវត្ថុដែលត្រូវបានរឹបអូសក្នុងការអនុវត្តដោយបង្ខំ ត្រូវធ្វើឡើងតាមរយៈ ការលក់ឡាយឡុងដោយផ្ទាល់មាត់ ឬដាក់ស្រោមសំបុត្រ ដោយអាជ្ញាសាលា។ ការលក់ដោយផ្ទាល់មាត់ ធ្វើឡើងដោយការស្នើចំនួនទឹកប្រាក់ថ្លៃទិញ បន្ទាប់មកអាជ្ញាសាលានឹងប្រកាសអនុញ្ញាតឲ្យទិញ ចំពោះអ្នកស្នើដែលហ៊ានឲ្យតម្លៃ ខ្ពស់ជាងគេ និងត្រូវបង់ថ្លៃទិញភ្លាម។ ចំពោះការលក់ដោយ ស្រោមសំបុត្រ ធ្វើឡើងដោយដាក់ពាក្យសុំទិញ ជាលាយលក្ខណ៍អក្សរ ហើយបន្ទាប់ពីបិទការដេញថ្លៃ អាជ្ញាសាលានឹងបើកស្រោមសំបុត្រ រួចប្រកាសឈ្មោះ និងថ្លៃរបស់បុគ្គលដែលហ៊ានឲ្យតម្លៃខ្ពស់ជាងគេព្រមទាំងអនុញ្ញាតឲ្យទិញ[12] ។

ទន្ទឹមគ្នានេះ នៅពេលកំពុងធ្វើការលក់ បើមានបុគ្គលណាធ្វើឲ្យរំខានដល់អ្នកស្នើទិញ ឬបានឃុបឃិតគ្នា បញ្ចុះតម្លៃលក់ អាជ្ញាសាលាអាចមិនអនុញ្ញាតឲ្យបុគ្គលនោះចូល ឬដេញចេញពីកន្លែងលក់ ឬមិនអនុញ្ញាតឲ្យ ស្នើទិញបាន[13] ។ ក្នុងករណីដែលការលក់មិនអាចធ្វើទៅបាន ទោះបីជាបានអនុវត្តការលក់តាមវិធីលក់ សមរម្យហើយក៏ដោយ ក៏នៅតែមិនអាចលក់បានដដែល ហើយព្យាករណ៍ឃើញថា នៅតែមិនអាចលក់បាននៅពេលអនាគតទៀត អាជ្ញាសាលាអាចសម្រេចលុបចោលនូវការរឹបអូសដែលបានធ្វើរួចហើយនោះបាន[14] ។

## ១.៧. ការរួមបញ្ចូលរឿងក្ដី

ក្នុងករណីដែលមានពាក្យសុំឲ្យអនុវត្ត ចំពោះចលនវត្ថុបន្ថែមទៀត ទៅលើកូនបំណុលដែលបានទទួលការរឹបអូសរួចហើយ នៅទីកន្លែងនៃការរឹបអូសដដែលនោះ ទោះបីជាមាន ចលនវត្ថុដែលមិនទាន់បានរឹបអូសនៅ

---

[10] មាត្រា ៣៨៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

[11] មាត្រា ៣៨៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

[12] មាត្រា ៣៩៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

[13] មាត្រា ៣៩៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

[14] មាត្រា ៣៩៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

ឡើយ ឬក៏គ្មានចលនវត្ថុដែលអាចរឹបអូសបានក៏ដោយ អាជ្ញាសាលាត្រូវរួមបញ្ចូលរឿងក្តីអនុវត្តចំពោះចលនវត្ថុថ្មី និងរឿងក្តីអនុវត្តចំពោះចលនវត្ថុមុន ជាមួយគ្នា។ ប្រសិនបើរឿងក្តីអនុវត្តចំពោះចលនវត្ថុទាំងពីរ ត្រូវបានរួមបញ្ចូលគ្នានោះ ចលនវត្ថុ ដែលត្រូវបានរឹបអូស ក្នុងរឿងក្តីក្រោយ ត្រូវចាត់ទុកថាបានរឹបអូសក្នុងរឿងក្តីមុន ហើយពាក្យសុំឲ្យអនុវត្តនៃរឿងក្តីក្រោយនេះ មានអានុភាពជាការទាមទារឲ្យចែកចំណែក។ នៅពេលរួមបញ្ចូលរឿងក្តី បើម្ចាស់បំណុលនៃការអនុវត្តមុន បានដកពាក្យសុំឲ្យអនុវត្ត ឬក៏នីតិវិធី ដែលបានចាប់ផ្តើមដោយពាក្យសុំនោះ ត្រូវបានផ្អាក ឬលុបចោល ចលនវត្ថុដែលត្រូវបានរឹបអូសក្នុងរឿងក្តីមុននោះ ត្រូវចាត់ទុកថា បានរឹបអូសក្នុងរឿងក្តីក្រោយ។ អនុវត្តដូចគ្នានឹងករណីខាងលើនេះដែរ បើរឿងក្តីនៃការអនុវត្តរឹបអូសជាបណ្តោះអាសន្ន និងរឿងក្តី នៃការអនុវត្តចំពោះចលនវត្ថុ ត្រូវបានរួមបញ្ចូលគ្នានោះ[15] ។

## ១.៨. ការទាមទារចំណែក និងការចែកចំណែក

នៅក្នុងនីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ បុគ្គលដែលមានឯកសិទ្ធិ ឬមានសិទ្ធិលើការបញ្ចាំ អាចទាមទារឲ្យចែកចំណែកមកឲ្យខ្លួនបាន ដោយការដាក់ឯកសារដែលបញ្ជាក់អំពីសិទ្ធិនោះ[16] ។ រីឯការចែកចំណែកវិញ ជាគោលការណ៍ត្រូវធ្វើដោយអាជ្ញាសាលា ហើយម្ចាស់បំណុល ដែលត្រូវទទួលបាន ចំណែកមានដូចជា៖ ម្ចាស់បំណុលនៃការអនុវត្ត ម្ចាស់បំណុលដែលត្រូវបានទទួលស្គាល់អានុភាពនៃការទាមទារ ឲ្យចែកចំណែក និងម្ចាស់បំណុលដែលបានទាមទារឲ្យចែកចំណែក។ ទោះបីជាម្ចាស់បំណុលមានតែម្នាក់ ឬមានច្រើននាក់ក៏ដោយ បើប្រាក់ដែលបានមក ពីការលក់ ឬប្រាក់ដែល ត្រូវបានរឹបអូស អាចសងបំណុលរបស់ម្ចាស់បំណុលនីមួយៗ និង សោហ៊ុយសម្រាប់ការអនុវត្តទាំងអស់បាន អាជ្ញាសាលាត្រូវចែកចំណែកដល់ម្ចាស់បំណុល ទាំងនោះ ហើយបើមានប្រាក់នៅសល់ត្រូវប្រគល់ឲ្យទៅកូនបំណុល នៃការអនុវត្តវិញ។ ផ្ទុយទៅវិញ ប្រសិនបើប្រាក់ដែលបានមកពីការលក់ ឬប្រាក់ដែលត្រូវបានរឹបអូសនោះ ពុំអាចសងម្ចាស់បំណុលនីមួយៗគ្រប់ទេ អាជ្ញាសាលាត្រូវកំណត់អំឡុងពេល ២សប្តាហ៍ ដើម្បីឲ្យម្ចាស់បំណុលទាំងអស់ ពិភាក្សាគ្នាលើការចែករំលែក ហើយបើពួកគេបានព្រមព្រៀងគ្នា ត្រូវចែកទៅតាមការព្រមព្រៀងនោះ[17] ។ ប៉ុន្តែ បើការព្រមព្រៀងលើ

[15] មាត្រា ៣៨៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

[16] មាត្រា ៣៩៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

[17] មាត្រា ៣៩៨ និង ៣៩៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

ការចែកចំណែកពុំបានសម្រេចទេ អាជ្ញាសាលាត្រូវរាយការណ៍អំពីហេតុការណ៍នោះ ទៅសាលាដំបូងដែលខ្លួនស្ថិតនៅ ដែលត្រូវទទួលបន្ទុកក្នុងការចែកចំណែកវិញ[18] ។

## ២. ការអនុវត្តសិទ្ធិប្រាតិភោគចំពោះចលនវត្ថុ

### ២.១. ការចាប់ផ្តើមអនុវត្តសិទ្ធិប្រាតិភោគ

ការចាប់ផ្តើមអនុវត្តសិទ្ធិប្រាតិភោគចំពោះចលនវត្ថុ មានលក្ខណៈស្រដៀងគ្នានឹង ការអនុវត្តដោយចំពោះចលនវត្ថុដែរ។ មានន័យថា ការអនុវត្តសិទ្ធិប្រាតិភោគចំពោះចលនវត្ថុ ត្រូវចាប់ផ្តើម ដោយការដាក់ពាក្យជាលាយលក្ខណ៍អក្សរសុំឲ្យអនុវត្តដោយបង្ខំ ដោយម្ចាស់សិទ្ធិប្រាតិភោគ ទៅអាជ្ញាសាលានៃសាលាដំបូងដែលស្ថិត នៅលើទីកន្លែងចលនវត្ថុនោះ ស្ថិតនៅដោយភ្ជាប់ជាមួយនឹងលិខិតអនុវត្ត។ នៅក្នុងពាក្យសុំឲ្យអនុវត្តត្រូវសរសេរនូវចំណុចដូចតទៅ ៖ សញ្ញាណនៃម្ចាស់បំណុល នៃការអនុវត្ត កម្មសិទ្ធិកររបស់ចលនវត្ថុដែលជាកូនបំណុល កូនបំណុលនៃសិទ្ធិលើបំណុលដែលត្រូវបានធានាសញ្ញាណ នៃសិទ្ធិប្រាតិភោគនិងសិទ្ធិលើបំណុលដែលបានត្រូវធានា សញ្ញាណនៃចលនវត្ថុដែលជាកម្មវត្ថុ និងទីកន្លែងនៃចលនវត្ថុនោះ[19] ។

លិខិតអនុវត្ត សម្រាប់យកមកអនុវត្តសិទ្ធិប្រាតិភោគចំពោះចលនវត្ថុមាន ២ ប្រភេទគឺ ៖

១. សាលក្រម ឬសាលដីកាស្ថាពរ ដែលបញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិប្រាតិភោគ ឬ លិខិតដែលមានអានុភាពដូចសាលក្រម ឬសាលដីការស្ថាពរនោះ។ លិខិតអនុវត្តនេះ គឺសំដៅលើសាលក្រម ឬសាលដីកាស្ថាពរដែលទទួលស្គាល់ការទាមទារឲ្យ បញ្ជាក់អំពីអត្ថិភាពនៃហ៊ីប៉ូតែក ឬដែលច្រានចោលការទាមទារឲ្យបញ្ជាក់អំពីនត្ថិភាពនៃ ហ៊ីប៉ូតែកហើយ និងកំណត់ហេតុស្តីពីការសះជា ឬកំណត់ហេតុទទួលស្គាល់ការទាមទារដែលមានអត្ថន័យ ដូចគ្នានឹងសាលក្រម ឬសាលដីកាខាងលើនេះ។

២. លិខិតយថាភូតដែលធ្វើឡើងដោយសារការី ហើយដែលបញ្ជាក់អំពីអត្ថិភាពសិទ្ធិប្រាតិភោគ គឺសំដៅ ទៅលើកិច្ចសន្យាបង្កើតហ៊ីប៉ូតែក ដែលធ្វើដោយសារការី[20] ។ ជាគោលការណ៍ ដើម្បីអាចអនុវត្តសិទ្ធិប្រាតិភោគចំពោះចលនវត្ថុបាន លុះត្រាតែមាន លិខិតអនុវត្តដូចបានរៀបរាប់ខាងលើ។

---

[18] មាត្រា ៤០១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

[19] មាត្រា ៥០២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

[20] មាត្រា ៤៩៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

ប៉ុន្តែទោះបីជាពុំ មានលិខិតអនុវត្តក៏ដោយក៏អាជ្ញាសាលាអាចចាប់ផ្តើមអនុវត្តសិទ្ធិប្រាតិភោគនោះបានដែរ ប្រសិនបើម្ចាស់បំណុលនៃការអនុវត្ត បានកាន់កាប់ចលនវត្ថុដែលជាកម្មវត្ថុដោយខ្លួនឯងហើយបានដាក់ចលនវត្ថុនោះ ឬបានដាក់ឯកសារដែលបញ្ជាក់ថា អ្នកកាន់កាប់ចលនវត្ថុនោះ បានយល់ព្រមចំពោះការរឹបអូស[21] ។

### ២.២. របៀបនៃការអនុវត្ត

ការអនុវត្តសិទ្ធិប្រាតិភោគចំពោះចលនវត្ថុ ត្រូវធ្វើឡើងដោយការរឹបអូសចលនវត្ថុដែល ជាកម្មវត្ថុ ដោយអាជ្ញាសាលាដូចគ្នានឹងការអនុវត្តដោយបង្ខំចំពោះចលនវត្ថុដែរ។ ដូចគ្នានេះដែរ ចំពោះរបៀបលក់ចលនវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគ ត្រូវធ្វើឡើងតាមវិធីដូចគ្នានឹងការ លក់ចលនវត្ថុ ដែលត្រូវបានរឹបអូសនៅក្នុងការអនុវត្តដោយបង្ខំ។ ម្យ៉ាងទៀត ការរួមបញ្ចូលរឿងក្តី ការទាមទារ ឲ្យចែកចំណែក និងនីតិវិធីនៃការចែកចំណែក ក៏ត្រូវធ្វើដូចគ្នានឹងការអនុវត្តដោយបង្ខំចំពោះចលនវត្ថុដែរ។

### ២.៣. ការអនុវត្តសិទ្ធិលើការបញ្ចាំដោយសង្ខេប

ការអនុវត្តសិទ្ធិលើការបញ្ចាំដោយសង្ខេប ជានីតិវិធីពិសេសមួយដែលផ្តល់ភាពងាយស្រួល និងឆាប់រហ័សក្នុងការអនុវត្តសិទ្ធិលើការបញ្ចាំ ។ បើកាតព្វកិច្ចមិនត្រូវបានអនុវត្តទេ ម្ចាស់សិទ្ធិលើការបញ្ចាំអាចដាក់ពាក្យទៅតុលាការ សុំឲ្យចេញដីកាសម្រេច អនុញ្ញាតឲ្យយកវត្ថុបញ្ចាំនោះមកសងដោយផ្ទាល់តែម្តង ព្រមទាំងអាចកំណត់តម្លៃដោយខ្លួនឯងបាន ដោយមានការយល់ព្រមពីកម្មសិទ្ធិករនៃវត្ថុបញ្ចាំ។ ក្នុងករណីនេះ ក្រោយពីបានដកនូវចំនួនទឹកប្រាក់នៃកាតព្វកិច្ចដែលត្រូវសង និងសោហ៊ុយ សម្រាប់នីតិវិធីរួចហើយ បើមានប្រាក់នៅសល់ត្រូវសងទៅឲ្យកម្មសិទ្ធិករនៃវត្ថុបញ្ចាំវិញ។ នៅពេលចេញដីកាសម្រេចអំពីពាក្យសុំខាងលើនេះ តុលាការត្រូវសួរម្ចាស់សិទ្ធិលើការបញ្ចាំ កម្មសិទ្ធិករនៃវត្ថុបញ្ចាំ និងកូនបំណុលនៃសិទ្ធិលើបំណុលដែលត្រូវបានធានាផងដែរ ហើយដីកាសម្រេចនេះអាចប្តឹងជំទាស់បាន[22] ។

### ២.៤. ការផ្អាក និងលុបចោលនូវការអនុវត្ត

ដើម្បីឲ្យនីតិវិធីនៃការអនុវត្តសិទ្ធិប្រាតិភោគផ្អាក និងធ្វើការលុបចោលនូវការចាត់ចែង ដែលបានធ្វើរួចហើយ លុះត្រាតែបានដាក់ឯកសារដូចខាងក្រោម ៖

---

[21] មាត្រា ៥០០ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

[22] មាត្រា ៥០៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

- ឯកសារចម្លងយថាភូតនៃសេចក្តីសម្រេចដែលកំណត់ថា លុបចោលលិខិតអនុវត្តក្នុងចំណុច ក នៃមាត្រា ៤៩៦ ។
- ឯកសាចម្លងយថាភូតនៃសេចក្តីសម្រេចដែលកំណត់ថា មិនអនុញ្ញាតឲ្យអនុវត្តសិទ្ធិប្រាតិភោគ។
- អនុសារសាលក្រម ឬអនុសារសាលដីកាដែលប្រកាសថា ការផ្សះផ្សា ឬការទទួលស្គាល់ដែលទាក់ទងនឹងលិខិតអនុវត្តនៅក្នុងចំណុចទី ១ នៃមាត្រា ៤៩៦ គ្មានអានុភាពអនុវត្ត។
- ឯកសារចម្លងយថាភូតនៃ កំណត់ហេតុអំពីការសះជាតាមនីតិវិធីតុលាការដែលកំណត់ថា មិនអនុវត្តសិទ្ធិប្រាតិភោគ ឬការដកពាក្យសុំឲ្យអនុវត្តសិទ្ធិប្រាតិភោគ។
- ឯកសារចម្លងយថាភូតនៃសេចក្តីសម្រេច ដែលកំណត់ការបង្គាប់ឲ្យផ្អាកការអនុវត្ត សិទ្ធិប្រាតិភោគ និងលុបចោលការចាត់ចែងការអនុវត្ត[23] ។

## ២.៥. អំពីបណ្តឹងតវ៉ា

### ក. ការតវ៉ានឹងការរឹបអូស

ប្រសិនបើការអនុវត្តសិទ្ធិប្រាតិភោគចំពោះចលនវត្ថុ ត្រូវបានចាប់ផ្តើមដោយពុំមានដាក់លិខិតអនុវត្តទេ កូនបំណុលនៃការអនុវត្ត ឬកូនបំណុលនៃសិទ្ធិលើបំណុល ដែលត្រូវបានធានា អាចដាក់ពាក្យសុំតវ៉ាទៅតុលាការដែលមានសមត្ថកិច្ច ដោយយកនត្ថិភាព ឬការរលត់នៃសិទ្ធិប្រាតិភោគនោះ មកធ្វើជាមូលហេតុបាន[24] ។

### ខ. សមត្ថកិច្ចលើបណ្តឹងតវ៉ាចំពោះលិខិតអនុវត្ត

ប្រសិនបើបណ្តឹងតវ៉ាប្រឆាំងនឹងការទាមទារ ដែលពាក់ព័ន្ធនឹងលិខិតអនុវត្តនៅក្នុង ចំណុច ក នៃមាត្រា ៤៩៦ គឺជាសមត្ថកិច្ចរបស់សាលាដំបូងដែលបានធ្វើនីតិវិធីនៃបណ្តឹងនោះ។ ម្យ៉ាងទៀត បើបណ្តឹងតវ៉ាចំពោះលិខិតអនុវត្ត នៅក្នុងចំណុច ខ គឺជាសមត្ថកិច្ចរបស់តុលាការដែលស្ថិតនៅលើទីកន្លែងរបស់ចុងចម្លើយ ឬស្ថិតនៅលើទីកន្លែង ដែលកម្មវត្ថុនៃសិទ្ធិប្រាតិភោគ ស្ថិតនៅ[25] ។

---

[23] មាត្រា ៤៩៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

[24] មាត្រា ៥០១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

[25] មាត្រា ៤៩៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

## ៣. ការអនុវត្តឲ្យប្រគល់អចលនវត្ថុ និងចលនវត្ថុ

### ៣.១. ការប្រគល់អចលនវត្ថុ

ការអនុវត្តដោយបង្ខំឲ្យប្រគល់អចលនវត្ថុ ឬនាវាផ្ទុក ឬវត្ថុផ្សេងទៀត ដែលមនុស្សរស់នៅក្នុងនោះ ត្រូវធ្វើតាមនីតិវិធីដែលអាជ្ញាសាលានៃសាលាដំបូងដែលមានសមត្ថកិច្ចលើកន្លែងដែលវត្ថុដែលជាកម្មវត្ថុស្ថិតនៅ រំលាយការកាន់កាប់វត្ថុ ដែលជាវត្ថុរបស់កូនបំណុលនៃការអនុវត្ត ហើយធ្វើឲ្យម្ចាស់បំណុលនៃការអនុវត្តទទួលបាន នូវការកាន់កាប់នោះ។ ការអនុវត្តដោយបង្ខំនេះ អាចធ្វើទៅបានលុះត្រាតែម្ចាស់បំណុលនៃការអនុវត្ត ឬអ្នកតំណាង របស់ម្ចាស់បំណុលនៃការអនុវត្តនោះ បានបង្ហាញខ្លួននៅកន្លែងអនុវត្ត។ ហើយអាជ្ញាសាលាអាចចូលទៅក្នុងអចលនវត្ថុ នាវា ឬវត្ថុផ្សេងទៀតដែលកាន់កាប់ដោយកូនបំណុលនៃការអនុវត្ត ហើយចាំបាច់សម្រាប់ធ្វើការចាត់ចែងដើម្បីបើកទ្វារ ដែលបិទនោះបាន[26] ។

ក្នុងការអនុវត្តខាងលើនេះ អាជ្ញាសាលាត្រូវដកចេញនូវវត្ថុដែលមិនមែនជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ ហើយត្រូវប្រគល់វត្ថុនោះទៅឲ្យកូនបំណុលនៃការអនុវត្ត ឬអ្នកតំណាងរបស់កូនបំណុលនោះ ឬញាតិនៅជាមួយ ឬអ្នកបំរើ ឬអ្នកផ្សេងទៀតដែលធ្វើការនៅទីនោះដែលមានការយល់ដឹងសមរម្យ។ ក្នុងករណីនេះ ប្រសិនបើពុំអាចប្រគល់ចលនវត្ថុនោះទៅឲ្យជនទាំងឡាយដែលរៀបរាប់ខាងលើទេ អាជ្ញាសាលាត្រូវថែរក្សាគ្រប់គ្រងវត្ថុនោះ ចំណែកឯការថែរក្សានេះ ត្រូវចាត់ជាសោហ៊ុយសម្រាប់ការអនុវត្ត។ ផ្ទុយមកវិញបើនៅតែមិនអាចប្រគល់ចលនវត្ថុនេះទៅឲ្យជនទាំងអស់ខាងលើនេះទេ អាជ្ញាសាលាអាចលក់វត្ថុនោះ តាមនីតិវិធីលក់នៃការអនុវត្តចំពោះចលនវត្ថុបាន ហើយប្រាក់ដែលបានពីការលក់នេះ អាជ្ញាសាលាត្រូវដកចេញនូវចំនួនទឹកប្រាក់ដែលមកពីការលក់នេះ សម្រាប់សោហ៊ុយនៃការថែរក្សា ហើយប្រាក់ដែលសេសសល់ត្រូវផ្ញើទៅសាលាដំបូងដែលខ្លួនស្ថិតនៅ[27] ។ បើបានបញ្ចប់ការអនុវត្តដោយបង្ខំដូចខាងលើហើយ អាជ្ញាសាលាត្រូវជូនដំណឹងទាំងនោះ ទៅកូនបំណុលនៃការអនុវត្ត[28] ។

---

[26] មាត្រា ៥២៤ ក.១ ដល់ ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

[27] មាត្រា ៥២៤ ក.៤ ដល់ ៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

[28] មាត្រា ៥២៤ ក.៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

### ៣.២. ការប្រគល់ចលនវត្ថុ

ការអនុវត្តដោយបង្ខំឲ្យប្រគល់ចលនវត្ថុ ត្រូវធ្វើតាមនីតិវិធីដែលអាជ្ញាសាលានៃសាលាដំបូងដែល មានសមត្ថកិច្ចលើកន្លែងដែលវត្ថុដែលជាកម្មវត្ថុស្ថិតនៅ ដកយកចលនវត្ថុពីកូនបំណុលនៃការអនុវត្ត ហើយប្រគល់ចលនវត្ថុនោះ ទៅឲ្យម្ចាស់បំណុលនៃការអនុវត្ត ។ ប្រសិនបើម្ចាស់បំណុលនៃការអនុវត្ត ឬអ្នកតំណាងពុំបានបង្ហាញខ្លួននៅទីកន្លែងធ្វើការអនុវត្តដោយបង្ខំ ដែលបានកំណត់ខាងលើទេ អាជ្ញាសាលាអាចព្យួរការអនុវត្តដោយបង្ខំបាន បើទទួលស្គាល់ថាពុំអាចជៀសវាង បានដោយគិតពិចារណាលើប្រភេទ និងចំនួនជាអាទិភាពនៃចលនវត្ថុដែលពាក់ព័ន្ធនោះ ។ ក្នុងស្ថានភាពស្រដៀងគ្នានេះ ម្ចាស់បំណុលនៃការអនុវត្ត ឬអ្នកតំណាងពុំបានបង្ហាញខ្លួននៅទីកន្លែងធ្វើការអនុវត្តដោយបង្ខំទេ បើជ្រុលជាបាន ដកហូតយកចលនវត្ថុនោះពីកូនបំណុលនៃការអនុវត្តដោយបង្ខំ អាជ្ញាសាលាត្រូវថែរក្សាគ្រប់គ្រង់វត្ថុនោះ[29] ។

## II. តួនាទីបន្ទាប់សន្សំរបស់អាជ្ញាសាលា

### ១. ការថែរក្សាគ្រប់គ្រងអចលនវត្ថុ

ប្រសិនបើគោលបំណង ឬអ្នកកាន់កាប់អចលនវត្ថុ បានប្រព្រឹត្តអំពើដែលធ្វើអោយតម្លៃអចលនវត្ថុនោះ ថយចុះគួរអោយកត់សំគាល់ ឬដែលធ្វើអោយមានការលំបាកដល់ការលក់ ឬការប្រគល់អចលនវត្ថុ ឬមានការបារម្ភថាអ្នកនោះនឹងប្រព្រឹត្តអំពើខាងលើនេះ តុលាកាអនុវត្តអាចហាមឃាត់ជន ដែលបានប្រព្រឹត្តអំពើទាំងនេះ ឬជនដែលត្រូវគេមានការបារម្ភ នឹងប្រព្រឹត្តអំពើទាំងនោះ ឬបង្គាប់អោយជននោះធ្វើសកម្មភាពណាមួយជាកំណត់ ឬបង្គាប់អោយជននោះលះបង់ការកាន់កាប់អចលនវត្ថុ ហើយអោយអាជ្ញាសាលាថែរក្សារ គ្រប់គ្រងអចលនវត្ថុនោះ បានដោយការសម្រេច តាមពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្ត អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមាឬទិញ អោយដាក់ ឬមិនអោយដាក់ប្រាតិភោគ។ ប៉ុន្តែមានតែករណីដែលអ្នកកាន់កាប់អចលនវត្ថុ មិនអាចយកមូលហេតុ គតិយុត្តនៃសិទ្ធិកាន់កាប់ តតាំងនឹងអ្នកទិញទេ ទើបអាចបង្គាប់អោយជននោះប្រគល់អចលនវត្ថុអោយអជ្ញាសាលា ដើម្បីអោយថែរក្សារគ្រប់គ្រងបាន[30] ។ បើស្ថានភាពប្រែប្រួល តុលាការអាចលុបចោល ឬកែប្រែដីកាសម្រេច ដោយយោងតាមពាក្យសុំនោះ ហើយពាក្យ សុំខាងលើនេះ អាចប្តឹងទាស់បាន[31] ។

---

[29] មាត្រា ៥២៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

[30] មាត្រា ៤២៩ ក.១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

[31] មាត្រា ៤២៩ ក.៣ និង ៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

ដីកាសម្រេចខាងលើនេះ ទោះជានៅមុនពេលដែលបានបញ្ជូនទៅភាគីម្ខាងទៀតក៏ដោយ ក៏អាចអនុវត្តបាន។ ចំពោះសោហ៊ុយសម្រាប់សុំ ឬការអនុវត្តដីកាសម្រេច ត្រូវចាត់ទុកជាសោហ៊ុយសម្រាប់ផលប្រយោជន៍រួមក្នុងនីតិវិធីនៃការលក់ដោយបង្ខំចំពោះអចលនវត្ថុនោះ[32] ។

## ២. ការអនុវត្តការលក់អចលនវត្ថុ

### ២.១. វិធីលក់

- ការលក់អចលនវត្ថុត្រូវអនុវត្តតាមវិធីលក់ឡាយឡុងដោយស្រោមសំបុត្រ រឺដោយផ្ទាល់មាត់។ វិធីលក់ឡាយឡុងដោយស្រោមសំបុត្រ រឺដោយផ្ទាល់មាត់ត្រូវបានកំណត់ដោយតុលាការអនុវត្ត ។
- ការលក់ដោយឡាយឡុងដោយស្រោមសំបុត្រ រឺ ដោយផ្ទាល់មាត់ តុលាការអនុវត្តត្រូវកំណត់កាលបរិច្ឆេទ និង ទីកន្លែងលក់អោយបានច្បាស់លាស់ហើយត្រូវអោយអាជ្ញាសាលាអនុវត្តការលក់នោះ។ ហើយម្យ៉ាងវិញទៀត ក្រឡាបញ្ជីត្រូវផ្សាយជាសាធារណៈ នូវសញ្ញាណអចលនវត្ថុដែលត្រូវលក់តម្លៃលក់អប្បបរមាព្រមទាំងកាល បរិច្ឆេទ និងទីកន្លែងលក់អោយបានច្បាស់លាស់ ។
- ការលក់តាមពីររបៀបនេះ អាជ្ញាសាលាអនុវត្ត ត្រូវរក្សាសណ្តាប់ធ្នាប់នៅកន្លែងលក់អោយមានរបៀបរៀបរយ ដែលមានចែងនៅក្នុងមាត្រា ៣៩៦ ដែលបានចែងថា ចំពោះជនណាដែលធ្វើសកម្មភាពរំខានកុំអោយការ អនុវត្តការលក់ធ្វើឡើងដោយត្រឹមត្រូវដូចជាបានធ្វើអោយរំខានដល់ជនដទៃទៀតក្នុងការធ្វើសំណើរទិញ រឺ ចំពោះជនដែលបានប្រើអោយធ្វើសកម្មភាពនោះអាជ្ញាសាលាអាចកម្រិតមិនអោយជននោះចូលកន្លែងលក់ រឺ អាចដេញជននោះចេញពីកន្លែងលក់ ឬ អាចមិនអោយស្នើសុំទិញបាន ។

### ២.២. ការកំណត់អ្នកស្នើទិញក្នុងតម្លៃអតិបរមា

- បើការលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ ដោយផ្ទាល់មាត់បានបញ្ចប់អាជ្ញាសាលាត្រូវប្រកាសការបញ្ចប់ កាលបរិច្ឆេទនៃការលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ ដោយផ្ទាល់មាត់ ក្រោយពេលបានកំណត់អ្នកស្នើ សុំទិញក្នុងតម្លៃអតិបរមា និង បានប្រកាសនូវនាម ឬ នាមករណ៍របស់អ្នកទិញ និង ថ្លៃលក់ឡាយឡុងនោះ ។

---

[32] មាត្រា ៥២៩ ក.៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

- បើអ្នកដេញថ្លៃដោយស្រោមសំបុត្រ ដែលបានធ្វើសំណើទិញក្នុងតម្លៃអតិបរមាមានច្រើននាក់ អាជ្ញាសាលា ត្រូវកំណត់អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា ដោយអោយអ្នកទាំងនោះដេញថ្លៃដោយស្រោមសំបុត្រម្តងទៀត ។ ក្នុងករណីអ្នកដេញថ្លៃមិនអាចដេញថ្លៃដោយតម្លៃតិចជាងតម្លៃដែលខ្លួនដេញមុនបានឡើយ ។

- បើសិនអ្នកដេញថ្លៃមិនបានធ្វើការធ្វើការដេញថ្លៃម្តងទៀតទេនោះ អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា ត្រូវបានកំណត់ដោយការចាប់ឆ្នោត ។ នៅពេលការលក់ឡាយឡុងធ្វើតាមពីររបៀបនោះ រួចរាល់ហើយ អាជ្ញាសាលាត្រូវធ្វើកំណត់ហេតុដែលបាន សរសេរដូចខាងក្រោមដាក់ជូនទៅតុលាការអនុវត្តភ្លាមៈ

  - សញ្ញាណនៃអចលនវត្ថុ
  - កាលបរិច្ឆេទនៃការលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ ផ្ទាល់មាត់
  - សញ្ញាណរបស់អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា
  - ហេតុការណ៍នោះ និងស្ថានភាពបើមិនអាចកំណត់អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា
  - មូលហេតុ និងវិធានការដែលបានចាត់ធ្វើដែលបានចាត់វិធានការដែលបានកំណត់ក្នុងមាត្រា ៣៩៦ ( ការរក្សាសណ្តាប់ធ្នាប់នៅកន្លែងលក់ )។

- អាជ្ញាសាលាត្រូវអោយអ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា ឬ អ្នកតំណាងចុះហត្ថលេខាលើកំណត់ហេតុនៃ ការលក់ឡាយឡុងដោយស្រោមសំបុត្រ ឬ ដោយផ្ទាល់មាត់ ។

- អាជ្ញាសាលាត្រូវអោយអ្នកស្នើទិញ ធ្វើការធានាលើសំណើរទិញ ដោយអោយជនដែលបម្រុងនឹងធ្វើសំណើ ទិញអចលនវត្ថុត្រូវដាក់ប្រាក់ធានាដែលមានចំនួនស្មើនឹងចំនួន ១ ភាគ ១០ ( មួយភាគដប់ ) នៃតម្លៃលក់អប្បបរមា ។ ប៉ុន្តែ បើយល់ឃើញថាសមរម្យ តុលាកាអនុវត្តអាចកំណត់ចំនួននៃប្រាក់ធានាលើសពីចំនួននេះបាន ។ ប្រសិនបើមានសំណើទិញពីបុគ្គលក្រៅពីអ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា តុលាកាអនុវត្តត្រូវសងភ្លាមនូវ ប្រាក់ធានាដោយផ្អែកលើបញ្ញត្តិនៃមាត្រា ៤៣៦ ( វិធីលក់ជាអាទិ៍ ) ។

### ៣. ការដកសញ្ជាតិនាវា

នាវា សំដៅដល់ជលយាន ដែលមានចំណុះសរុបជាតោនស្មើនឹង និងមិនលើសពី ២០តោន ទោះមិនបានចុះបញ្ជី នៅព្រះរាជាណាចក្រកម្ពុជាក៏ដោយ និងជលយានដែលមានចំណុះសរុបជាតោន ក្រោម ២០តោន ដែល

បានចុះបញ្ជីនៅព្រះរាជាណាចក្រកម្ពុជា[33] ។ លិខិតបញ្ជាក់លិខិតនាវា សំដៅទៅលើឯកសារដែលបញ្ជាក់សញ្ជាតិនាវា និងឯកសារផ្សេងទៀតដែលចាំ បាច់ដើម្បីបើកបរនាវាដោយស្របច្បាប់[34] ។ ការដកហូតសញ្ជាតិនាវាត្រូវធ្វើដោយមូលហេតុខាងក្រោម៖

- ក្នុងករណីមានការព្រួយបារម្ភថានឹងមានការលំបាកខ្លាំង ក្នុងការអនុវត្តដោយបង្ខំចំពោះនាវា បើមិនដកហូត យកលិខិតបញ្ជាក់សញ្ជាតិនាវានោះ ជាអាទ៍ នៅមុនការដាក់ពាក្យសុំឲ្យអនុវត្តដោយបង្ខំចំពោះនាវាទេ សាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលនាវានោះត្រូវបានចុះបញ្ជី អាចចេញដីកាសម្រេចបង្គាប់ ឲ្យកូនបំណុលនៃការអនុវត្ត ប្រគល់លិខិតបញ្ជាក់សញ្ជាតិវានាជាអាទ៍ទៅអោយអាជ្ញាសាលាតាមពាក់សុំ ។ បើនាវានោះពុំបានចុះបញ្ជីទេ ឬ បើមានស្ថានភាពជាបន្ទាន់ សាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែង ដែលនាវានោះស្ថិតនៅ អាចចេញដីកាសម្រេចបាន។

- ដើម្បីដាក់ពាក្យសុំតាមបញ្ជា ម្ចាស់បំណុលនៃការអនុវត្ត ត្រូវបង្ហាញនៅឯកសាចម្លងយថាភូត នៃលិខិតអនុវត្តដែលមានអានុភាពអនុវត្ត ហើយត្រូវធ្វើសេចក្តីបញ្ជាក់អំពីមូលហេតុ បានកំណត់នៅក្នុងកថាខណ្ឌទី១នេះ ។ ដីកាសម្រេចនេះ ត្រូវបញ្ជូនទៅឲ្យកូនបំណុលនៃការអនុវត្ត ហើយដីកាសម្រេចនេះផងដែរ អាចប្តឹងជំទាស់បាន។

- ចំពោះដីកាសម្រេចនេះ ទោះនៅមុនពេលបញ្ជូនទៅអោយកូនបំណុលនៃការអនុវត្តក៏ដោយ ក៏អាចអនុវត្តបានដែរ។ សោហុយចាំបាច់សម្រាប់ការអនុវត្តនេះ ត្រូវចាត់ជាសោហុយសម្រាប់ផលប្រយោជន៍រួមក្នុងនីតិវិធីនៃការលក់ ដោយបង្ខំ។

- ដីកាសម្រេចបង្គាប់ឲ្យប្រគល់លិខិតបញ្ជាក់សញ្ជាតិនាវាជាអាទ៍ទៅឲ្យអាជ្ញាសាលា ខាងលើនេះពុំត្រូវអនុវត្តឡើយ បើហួសអំឡុងពេល២សប្តាហ៍ គិតចាប់ពីថ្ងៃបានជូនដំណឹងទៅឲ្យម្ចាស់បំណុលនៃការអនុវត្ត។ បើម្ចាស់បំណុលនៃ ការអនុវត្តមិនបានដាក់លិខិតដែលបញ្ជាក់ថា ខ្លួនបានដាក់ពាក្យសុំឲ្យអនុវត្តដោយបង្ខំចំពោះនាវា នៅក្នុងអំឡុង ពេល៥ថ្ងៃ គិតចាប់ពីថ្ងៃដែលបានទទួលការប្រគល់លិខិតបញ្ជាក់នាវា ជាអាទ៍នោះទេ អាជ្ញាសាលាត្រូវសងលិខិត បញ្ជាក់នាវាជាអាទ៍នោះទៅកូនបំណុលនៃការអនុវត្តវិញ។

---

[33] មាត្រា ៤៥៤ ក.១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

[34] មាត្រា ៤៥៤ ក.២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

## សេចក្តីសន្និដ្ឋាន

អាជ្ញាសាលា ជាស្ថាប័នយុត្តាធិការឯករាជ្យមួយ ដែលទទួលបន្ទុកធ្វើការបញ្ជូនឯកសារនានា ដែលចេញដោយតុលាការនិងធ្វើការអនុវត្តដោយបង្ខំមួយចំនួនដែលច្បាប់កំណត់។ ដែលច្បាប់កំណត់ក្នុងទីនេះ គឺសំដៅដល់តួនាទីនិងភារកិច្ច។ ចំពោះតួនាទីក្រុមយើងខ្ញុំបាន ធ្វើការបែងចែកជា២ផ្នែកធំៗដូចជា៖ គឺផ្នែកទី១ គឺតួនាទីគោល ដែលចែកជា៣ចំណុចទៀតដូចជា៖ ការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ, ការអនុវត្តសិទ្ធិ ប្រាតិភោគចំពោះចលនវត្ថុ និងការអនុវត្តឲ្យប្រគល់ចលនវត្ថុនិងអចលនវត្ថុ។ ឯផ្នែក១ទៀតគឺ តួនាទីបន្ទាប់បន្សំរបស់អាជ្ញាសាលា ដែលក្នុងទីនេះ ចែកជា៣ចំណុចដូចគ្នា ដែលរួមមាន៖ ការថែរក្សា គ្រប់គ្រងអចលនវត្ថុ ការអនុវត្តការលក់អចលនវត្ថុ និងការដេកសញ្ញាតិនាវា។

## ឯកសារយោង


- ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦ ។
- សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគ ២ ។
- សេចក្តីព្រាងច្បាប់ស្តីពីអាជ្ញាសាលា ឆ្នាំ២០១២ ។
- ប្រកាសលេខ ៣០ ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ២០០៧ របស់ក្រសួងយុត្តិធម៌ ។